**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

លេខ : ៧៤២/២៣ មស.សជណ

ថ្ងៃ ពុធ ១០រោច ខែ មាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៥ខែកុម្ភៈ ឆ្នាំ២០២៣

# សេចក្ដីជូនដំណឹង

យោងតាមសេចក្ដីជូនដំណឹងរបស់ក្រសួងមុខងារសាធារណៈ លេខៈ ៤៣៥/២៣ មស.សជណ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣ ស្ដីពីការប្រឡងជ្រើសរើសមន្ត្រីរាជការដែលមានលក្ខណៈសម្បត្តិសមស្រប ឱ្យទទួលមុខតំណែងជាអនុប្រធាននាយកដ្ឋាននីតិកម្ម នៃអគ្គនាយកដ្ឋានកិច្ចការទូទៅ ដើម្បីបំពេញបន្ថែមលើចំនួនអនុប្រធាននាយកដ្ឋានដែលមានស្រាប់។

អាស្រ័យហេតុនេះ ក្រសួងមុខងារសាធារណៈ សូមជម្រាបជូនដំណឹងបន្ថែមដល់មន្ត្រីរាជការគ្រប់ក្រសួង ស្ថាប័នទាំងអស់ដែលមានចំណាប់អារម្មណ៍ សូមអញ្ជើញមកទទួលពាក្យស្នើសុំចូលរួមការប្រឡង នៅនាយកដ្ឋានគ្រប់គ្រងបុគ្គលិក នៃទីស្ដីការក្រសួងមុខងារសាធារណៈ ចាប់ពីពេលជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣។

មន្ត្រីរាជការទាំងអស់ត្រូវមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- មានសញ្ញាបត្រផ្នែកនីតិសាស្ត្រ ឬផ្នែករដ្ឋបាលសាធារណៈ ឬផ្នែកជំនាញប្រហាក់ប្រហែល
- មានបទពិសោធន៍ការងារចាប់ពី ៣ឆ្នាំឡើងទៅ
- មានសមត្ថភាពអាចប្រើប្រាស់ភាសាបរទេសបាន
- ចេះធ្វើការជាក្រុម។

ព័ត៌មានលម្អិតបន្ថែម៖ លេខទូរស័ព្ទ 012 811 977, 017 779 998 និង 012 558 126។/.

ត.ប.**រដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**
**អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ**

**សយ ឆេតនៈ**

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh